ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិថ្មី សម្រាប់រយៈពេល ៣ ឆ្នាំ (២០១៦-២០១៨)

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភូមិថ្មី |
| ភូមិ | ៖ | ភូមិថ្មី |
| សង្កាត់ | ៖ | សាមគ្គី |
| ក្រុង | ៖ | ស្ទឹងត្រែង |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍ភូមិថ្មី
# សម្រាប់រយៈពេល ៣ ឆ្នាំ (២០១៦-២០១៨)

សហគមន៍នេសាទ ៖ ភូមិថ្មី
ភូមិ ៖ ភូមិថ្មី
សង្កាត់ ៖ សាមគ្គី
ក្រុង ៖ ស្ទឹងត្រែង
ខេត្ត ៖ ស្ទឹងត្រែង

២០១៥

## ២០១៥

### មាតិកា

**១.ស្ថានភាពទូទៅ**......................................................................................................៤
**២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម**....................................................................................៥
ក.ប្រជាពលរដ្ឋ ......................................................................................................៥
ខ. មុខរបរ ......................................................................................................៥
**៣.កន្លែងនេសាទ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**.................................................៦
ក. ទីតាំង ......................................................................................................៦
ខ. ដែននេសាទ......................................................................................................៦
ខ.១.អូរ ......................................................................................................៦
ខ.២.កោះ ......................................................................................................៧
ខ.៣.ប្រឡាយ......................................................................................................៧
ខ.៤.អន្លង់......................................................................................................៧
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស......................................................................៨
ឃ. ធនធានជលផល ......................................................................................................៨
១.ប្រភេទត្រី ......................................................................................................៨
២.ប្រភេទវារីសត្វ ......................................................................................................៨
៣.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ......................................................................៩
**៤.ការធ្វើនេសាទ** ......................................................................................................៩
ក.អ្នកនេសាទ......................................................................................................៩
ខ.ឧបករណ៍នេសាទ ......................................................................................................៩
គ.ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ ......................................................................១១
**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ......................................................................១១
ក.ទស្សនៈវិស័យ ......................................................................................................១១
ខ.គោលបំណង ......................................................................................................១១
គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍......................................................................១១

គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ..........១១
គ.២. ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ ..........១២
គ.៣. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ..........១៣
គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ..........១៤
គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ..........១៤
គ.៦. ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព ..........១៥
គ.៧. ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ ..........១៧
គ.៨. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ..........១៨
គ.៩. ផែនការផ្សព្វផ្សាយបង្កើនការយល់ដឹងដល់សមាជិកសហគមន៍..........១៨
គ.១០. ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍន៍សហគមន៍..........១៩
ឃ. យុទ្ធសាស្ត្រ..........២០
**៦.ឧបសម្ពន្ធ**
ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០១៦-២០១៨..........២១
ឧបសម្ពន្ធ ៖ តារាងកម្មវិធីការងារឆ្នាំ២០១៦-២០១៨..........៣២

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ១.ស្ថានភាពទូទៅ

សហគមន៍នេសាទភូមិថ្មី ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៣ បានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែងលើកទី១នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង លើកទី២នៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១៦ ដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅក្នុងភូមិថ្មី សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ដែលមានសមាជិកសហគមន៍នេសាទសរុបចំនួន១៥២គ្រួសារ ស្មើនឹង៤៧២នាក់ (ស្រីចំនួន២៤៨នាក់) និងមានគណៈកម្មការចំនួន ៧ នាក់/ស្រីចំនួន ០២ នាក់។ សហគមន៍នេសាទភូមិថ្មី ត្រូវបានក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

នៅពេលដែលសហគមន៍នេសាទត្រូវបានបង្កើតនៅឆ្នាំ២០០០ សកម្មភាពដែលកើតក្នុងតំបន់ដូចជា: ការកាប់បំផ្លាញព្រៃលិច ការប្រើឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់គ្រឿងផ្ទុះ ឧបករណ៍ឆក់ មងក្រឡាធំៗ កាប់ព្រៃលិចទឹក និងសារជាតិពុល)ជាដើម។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមក សហគមន៍នេសាទក៏អនុវត្តសកម្មភាពសំខាន់ៗរបស់ខ្លួនដូចជា: រៀបចំភារៈកិច្ចទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ រៀបចំក្រុមល្បាត រៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង ចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទ ចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា ចុះល្បាតជាប្រចាំដោយសហការជាមួយខណ្ឌរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជល ផលដែលកើតមាននៅក្នុងកន្លែងនេសាទសហគមន៍។

នៅឆ្នាំ ២០០៦ រហូតដល់បច្ចុប្បន្ន សហគមន៍នេសាទបានធ្វើការអះអាងពីការជោគជ័យរបស់ខ្លួន ក្នុងការលុបបំបាត់ការកាប់ព្រៃលិចទឹកបាន ៨៥ % និងបានកាត់បន្ថយសកម្មភាពបទល្មើសនេសាទដែលធ្វើឲ្យផលនេសាទមានការកើនឡើង។ ការរីកចំរើនដោយសារតែអ្នកភូមិមានការយល់ដឹង ការចូលរួមពីសហគមន៍ និងតម្រូវការលើធនធានធម្មជាតិ ជាពិសេសធនធានជលផល។ សហគមន៍នេសាទមានការទំនាក់ទំនងល្អ និងកិច្ចសហការណ៍ល្អជាមួយអាជ្ញាធរមូលដ្ឋាន អាជ្ញាធរដែនដី និងស្ថាប័នជំនាញជលផល មន្ទីរបរិស្ថានក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល។

## ២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

សហគមន៍នេសាទភូមិថ្មី ចំនួនប្រជាពលរដ្ឋសរុប ១៨៦ គ្រួសារ ស្មើនឹង ៨៧៨ នាក់ (ស្ត្រី ៥៥១នាក់) នៅក្នុងនោះមានជនជាតិខ្មែរចំនួន ១០០%។

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ២៣ នាក់

-ចំនួនបុរសពោះម៉ាយក្នុងសហគមន៍មាន ០៤នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមានប្រុស ២០ នាក់ (ស្រី ១៤ នាក់)

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៤២ នាក់ (ស្រី ២០ នាក់)

-ចំនួនអ្នកមានជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ០៦ នាក់ (ស្រី ០៥ នាក់)

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ០២ នាក់ (ស្រី ០១នាក់)

ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន ៩៩% សាសនាកាតូលិក ប្រមាណ ១% (១គ្រួសារស្មើ ១២នាក់)។

ក្នុងចំណោមសមាជិក នៃសមាជិកសហគមន៍នេសាទភូមិថ្មីទាំងអស់ អ្នកមិនចេះអក្សរមាន ចំនួន ១០៤នាក់ (ស្រី២៩នាក់) កំរិតថ្នាក់បឋមសិក្សាចំនួនសរុប ២៥១ នាក់ (ស្រី ១០៦នាក់) កំរិតមធ្យមសិក្សាចំនួនសរុប ២៨នាក់ (ស្រី១៨នាក់) កំរិតវិទ្យាល័យចំនួន ៨២នាក់ (ស្រី៤៨នាក់) និងកំរិតសកលវិទ្យាល័យមានចំនួន ០៧នាក់ (ស្រី០៤នាក់)។

### ខ.មុខរបរ

**មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន**

-អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួនសរុប ១៦៧ គ្រួសារ ស្មើនឹង ៨៩.៧៨%

-ធ្វើស្រែចំនួន ៨០ គ្រួសារ ដែលមានទំហំដីសរុបចំនួន ១២០ ហិកតា

-ធ្វើចំការចំនួន ១០ គ្រួសារ/ទំហំដីចំការ ២០ ហិកតា (អ្នកដាំដំណាំលក្ខណៈយូរអង្វែង ដូចជាៈ ក្រូចពោធិសាត់ និង ដាំដំណាំចំរុះដូចជាៈពោត សណ្តែក សណ្តែកសៀង ស្រូវ និង ល្ង)

-ដាំបន្លែជាលក្ខណៈគ្រួសារចំនួន ១៤៨ គ្រួសារ ទំហំដីសរុប ៥ហិកតា (សួនច្បារជាលក្ខណៈគ្រួសារដែល មាទំហំ ៣ x ៥ ម៉ែត្រ)

-លក់ដូរជាអាជីព ១២ គ្រួសារ

-ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ១០០% នៃ ១៨៦ គ្រួសារក្នុងភូមិ

-កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួនសរុប ១០០ គ្រួសារ ក្នុងនោះមានដូចជាធ្វើផ្អក ប្រហុក ត្រីប្រៃ ជាដើម។ ក្នុងមួយគ្រួសារអាចផលិតបានចំនួនពី ១០ គីឡូក្រាមទៅ ២០ គីឡូក្រាមក្នុង/១ឆ្នាំ

-ជាងធ្វើទូក ០៤ នាក់

-ពេទ្យសត្វ ០២ នាក់

-ជាងជួសជុលម៉ូតូ ០១ នាក់

-ជាងផ្ទះ ០៧ នាក់

-មន្ត្រីរាជការ ១១នាក់

-ចំណាកស្រុកទៅប្រទេសម៉ាឡេស៊ីស្រី ០២នាក់ ទៅកូរ៉េប្រុស ០៣នាក់ ទៅថៃ០៨នាក់ (ស្រី០២នាក់)។

**៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

**ក.ទីតាំង**

កន្លែងនេសាទសហគមន៍ភូមិថ្មី ជាដែននេសាទសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍ភូមិថ្មីមានទំហំ ៣២៣ ហិកតា និងមានកំណត់និយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

<u>មានព្រំប្រទល់</u> ៖

-ខាងជើងទល់នឹង កន្ទុយកោះកាង/ប៉ុងតាឡាំជាប់សហគមន៍នេសាទអន្លង់កោះកាង

-ខាងត្បូងទល់នឹង អូរតាប្លក់

-ខាងកើតទល់នឹង ត្រើយខាងភូមិថ្មី

-ខាងលិចទល់នឹង ត្រើយកោះស្នាមជ័យ

**ខ.ដែននេសាទ**

កន្លែងនេសាទសហគមន៍ភូមិថ្មី មានវិសាលភាពនៅក្នុងទន្លេមេគង្គដែលក្នុងនោះរួមមាន៖អូរចំនួន ០៦ អូរ កោះចំនួន ០៥ កោះ ប្រឡាយចំនួន ០៥ ប្រឡាយ និងអន្លង់ចំនួន ០៧ អន្លង់។

**ខ.១ អូរ**

| ឈ្មោះអូរ | ប្រវែង (ម ) | រដូវនេសាទ |
|---|---|---|
| អូរតាប្លក់ | ២០០ | ខែ ០៨ - ខែ ១១ |
| អូរតាកេះ | ១០០ | ខែ ០៨ - ខែ ១១ |
| អូររ៉ឺនឌុក | ២០០ | ខែ ០៨ - ខែ ១១ |

| | | |
|---|---|---|
| អូររ៉ឺនសាន់ | ១៥០ | ខែ ០៨ - ខែ ១១ |
| អូរតាឡូន(អូរយាយប្រលិត) | ២០០ | ខែ ០៨ - ខែ ១១ |
| អូរតាផុត | ១០០ | ខែ ០៨ - ខែ ១១ |

### ខ.២ កោះ

| ឈ្មោះកោះ | ទទឹង និងបណ្តោយ(ម៉ែត្រ) | ទំហំសរុប (ហិកតា) |
|---|---|---|
| កោះស្នាមជ័យ | ៥០០ x ៣០០ | ១៥ ហិកតា |
| កោះត្រែង | ៧០ x ៣០០ | ៧ ហិកតា |
| កោះខៀវ | ៥០ x ២០០ | ១ ហិកតា |
| កោះតាផុន | ២៥ x ៧០ | ០.១៧ ហិកតា |
| កោះតាបូ | ៣០ x ៨០ | ០.២៤ ហិកតា |

### ខ.៣ ប្រឡាយ

| ឈ្មោះប្រឡាយ | បណ្តោយ(ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ប្រឡាយតាបែ | ៥០ | នេសាទមិនបាន |
| ប្រឡាយតាសឺន | ៥០ | នេសាទមិនបាន |
| ប្រឡាយតាវែន | ១០០ | ខែ ០៨ - ខែ ០៩ |
| ប្រឡាយតារុជ | ១០០ | ខែ ០៨ - ខែ ០៩ |
| ប្រឡាយតាសុខ | ២០ | នេសាទមិនបាន |

### ខ.៤ អន្លង់

| ឈ្មោះអន្លង់ | ទទឹង និង បណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់រ៉ឺនឌុក | ៧០ x ១០០ | ៧.០០០ | ៧០ | ៦០ |
| អន្លង់រ៉ឺនតាចូ | ៧០x ៧០ | ៤.៩០០ | ៥០ | ៤០ |

| | | | | |
|---|---|---|---|---|
| អន្លង់កន្ទុយកោះត្រែង | ៣០ x ៣០ | ៩០០ | ៨០ | ៧០ |
| អន្លង់តាឡួន | ៥០ x ១០០ | ៥០០០ | ៥០ | ៤០ |
| អន្លង់វ៉ឺនសាន់ | ៨០ x ២០០ | ១៦.០០០ | ៥០ | ៤០ |
| អន្លង់តាឡាំ | ១៥០ x ២០០ | ៣០.០០០ | ៣០ | ២០ |
| អន្លង់កន្ទុយកោះកាង | ១០០ x ១០០ | ១០.០០០ | ៧០ | ៦០ |

កន្លែងនេសាទសហគមន៍ភូមិថ្មីមានផ្ទៃដីព្រៃលិចទឹកទំហំសរុប ១០៥ ហិកតា ក្នុងនោះមានប្រភេទព្រៃដើមរំដេងទំហំ ៥ ហិកតា និងព្រៃលិចទឹកចំរុះទំហំ ១០០ ហិកតានៅក្នុងកន្លែងនេសាទសហគមន៍ភូមិថ្មី។

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

សហគមន៍នេសាទភូមិថ្មីបានឯកភាពគ្នាយកតំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន០១ គឺ អន្លង់វ៉ឺនឌុក។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់វ៉ឺនឌុក | ៧០ x ១០០ | ៧.០០០ | ៧០ | ៦០ |

**ឃ.ធនធានជលផល**

**១.ប្រភេទត្រី៖** ត្រីរស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ចង្វា កំភ្លាញ ឆ្ពួញ ខ្មាន់ ឆ្ពិន ច្រកែង កន្ត្រប់ ត្រីដំរី កញ្ចុះក្រុះ កញ្ជ្រូក កាហែ ត្រីលិញ ត្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឫស្សី ត្រីខ្ញឹង ត្រីខ្យា ត្រីកេះ ឆ្តោក ត្រីកែ ត្រីត្រសក់ ត្រីគល់រាំង ត្រីអណ្តែង ត្រីក្អែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីក្លាំងហាយ ត្រីឆ្វា ត្រីក្របី ត្រីកន្ត្រង់ប្រេង ត្រីឫសចេក ត្រីក្តុក ត្រីគ្រំ ត្រីកំបុតច្រមុះ ត្រីខ្យាថ្ម ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ា ត្រីអាចម៍កុក។

**២.ប្រភេទវារីសត្វ** (ក្តាម ខ្យង ខ្ចៅ គ្រំ លៀស អណ្តើក កន្ធាយ ពស់ កំពិស កង្កែប ហ៊ីងគីង្គក់។

**៣.ប្រភេទបក្សី៖** កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ រនាលខ្យង ក្រសារ ខ្លាត្រី ក្អែកទឹក ក្អែកគោក...) ។

**៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងរាវីរុក្ខជាតិៈ** ដើមត្រែង ដើមអញ្ចេង ដើមរំចេក ដើមអណ្តែង ដើមត្រស់ ដើមរាំង ដើមល្វា ដើមផ្ទាទឹក ដើមក្តុល ដើមជ្រៃ ដើមព្រីង ដើមញ ដើមព្រុះទឹក ដើមទន្លាត ដើមក្របៅ ដើមចេកទុំ ដើមពោធិ ដើមបន្លាឃ្លេ។

## ៤ ការធ្វើនេសាទ

### ក.អ្នកនេសាទ

១.អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១៥២ គ្រួសារ

២.អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៣៩គ្រួសារ

៣.ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៣០គ្រួសារ

### ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទៈ

| ឧបករណ៍នេសាទ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ដៃ | ១៤៨គ្រួសារ x ៤ =៥៩២ដៃ | ក្រឡា២.៥០-១២ស.ម និងជម្រៅ១-៣ម | ខែ ០៣-ខែ ០៦ |
| សន្ទូច | ផ្លែ | ៩១គ្រួសារ x ២០០ =១៨.២០០ផ្លែ | ផ្លែលេខ ១២-០៨ | នេសាទពេញ ១ ឆ្នាំ |
| លប | លប | ១គ្រួសារ =៥គ្រឿង | មុខកាត់ ០.៥០ម ប្រវែង១.២០ម | ខែ ០៦-ខែ ១១ |
| សំណាញ់ | វង់ | ៩គ្រួសារ x១=៩ | សំរុង៣.៥០-៥.៥០ម | នេសាទពេញ ១ ឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួនគ្រួសារ | ចំនួនម៉ាស៊ីន | កំលាំងសេះ |
|---|---|---|---|
| ទូកអ៊ុំ ទូកចែវ | ១ | ១ | ០ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ២ | ២ | ៥.៥ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ៤ | ៤ | ៦ |
| ទូកអេរជាប់ម៉ាស៊ីន HONDA & HINOTA | ៨១/៣ | ៨១/៣ | ៦.៥០ |
| ទូកអេរជាប់ម៉ាស៊ីន HONDA& HINOTA | ៣/៣ | ៣/៣ | ៧ |
| ទូកអេរជាប់ម៉ាស៊ីន HONDA& HINOTA | ២/១ | ២/១ | ៧.៥ |

| | | | |
|---|---|---|---|
| ទូកអេរជាប់ម៉ាស៊ីន HINOTA | ១ | ១ | ៨ |
| ទូកអេរជាប់ម៉ាស៊ីន HONDA& HINOTA | ១៩/១ | ១៩/១ | ៩ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ៣ | ៣ | ៩.៥ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ៧ | ៧ | ១៣ |
| ទូកអេរជាប់ម៉ាស៊ីន HINOTA | ១ | ១ | ១៨ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ១ | ១ | ២៥ |
| **សរុប** | **១៣៣គ្រួសារ** | **១៣៣ គ្រឿង** | **៥-២៥ សេះ** |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

| ឧបករណ៍នេសាទ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| មង | ម៉ែត្រ | ១៦០គ្រួសារ x ១០០ =១៦.០០០ ម៉ែត្រ | ក្រឡា២.៥០-១៣ស.ម និងជម្រៅ១-៣ ម | ខែ ១១ - ខែ ០៣ |
| សន្ទូច | ផ្លែ | ១៦០គ្រួសារ x ១០០ =១៦.០០០ | (១០០ផ្លែលេខ៥-១៨) | ខែ ១១ - ខែ ០៣ |

| ប្រភេទទូក កាណូត | ចំនួនគ្រួសារ | ចំនួនទូក | ចំណុះ (គក្រ) | កំលាំងសេះ |
|---|---|---|---|---|
| ទូកអេរជាប់ម៉ាស៊ីន HONDA | ១០០ | ១០០ | ៣០០- ៤០០ | ១៣ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ៦០ | ៦០ | ៣០០- ៤០០ | ១៨ |
| **សរុប** | **១៦០ គ្រួសារ** | **១៦០គ្រឿង** | **៣០០-៤០០គ.ក** | **១៣-១៨សេះ** |

### គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសា(គិតជាគក្រ) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៩០ | ៧០ | ១៦៥ |
| ក្តាម ខ្យង ខ្ចៅ | ១ | ៥ | ៥ |
| កំពឹស | ០.៥០ | ០.៣០ | ០.៨០ |
| **សរុបរួម** | **៩១.៥** | **៧៥.៥** | **១៧០.៨** |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទភូមិថ្មី មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

-ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទកន្លែងអន្លង់អភិរក្សព្រៃលិចទឹក

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋ ខ្មែរប្រកបដោយសមធម៌

-ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ

### គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

#### គោលបំណង

-ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

**ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖**

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន/គ្រួសារ | |
| ១ ក្នុងទន្លេមេគង្គ | នេសាទពេញ មួយឆ្នាំជា លក្ខណៈគ្រួសារ | មង | ជម្រៅ ៣ ម៉ែត្រ | ១០០ម៉ែត្រ | |
| | | ចាន់ | មុខកាត់៣០-៥០ស.ម ប្រវែង ១ ម៉ែត្រ | ៥គ្រឿង | |
| | | លប | មុខកាត់០.៨០មប្រវែង១.៥០ | ៣គ្រឿង | |

| | | | | | |
|---|---|---|---|---|---|
| | រដូវបិទ នេសាទ ៥០ ម | សំណាញ់ | ជម្រៅ ៣-៥ ម៉ែត្រ | ១វង់ | |
| | | សន្ទូចរនង | ផ្លែលេខ១២-៧ | ១០០ផ្លែ | |
| ២ ទំនាបអូរលិច ទឹករដូវវស្សា | ខែ៨ - ខែ ១២ | មង | ជម្រៅ ៣ ម៉ែត្រ | ៣០ម៉ែត្រ | |
| | | សំណាញ់ | ជម្រៅ ៣-៤ ម៉ែត្រ | ១វង់ | |
| | | សន្ទូចរនង | ផ្លែលេខ១២-៧ | ៥០ផ្លែ | |
| | | លប | មុខកាត់ ០.៨០ម ប្រវែង ១.៥០ម | ៥គ្រឿង | |
| | | ទ្រូ | មុខកាត់ ០.៣០ម ប្រវែង ១.៥ម | ៣គ្រឿង | |

**គ.២ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍**

**គោលបំណង**

-កំណត់បានព្រំប្រទល់ច្បាស់លាស់នៃសហគមន៍នេសាទភូមិថ្មី

-សមាជិកនិងប្រជាពលរដ្ឋបានស្គាល់កន្លែងនេសាទសហគមន៍

| ឈ្មោះដែន នេសាទ | ទំហំ/ចំនួន | សកម្មភាព | អ្នកទទួល ខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទ សហគមន៍ន ភូមិថ្មី ៣២៣ ហិកតា | បង្គោលព្រំធ្វើពី ស៊ីម៉ងចំនួន ២០ បង្គោល | -រៀបចំក្រុមបោះបង្គោល<br>-ទិញបង្គោលនិងយុទ្ធនាការចុះបោះបង្គោល<br>-ផ្សព្វផ្សាយជាសាធារណៈ | -គណៈកម្មការ<br>-សមាជិកស.ន<br>-មេភូមិ មេឃុំ | ២០១៦ | ២០១៧ |
| | ផ្ទាំងប៉ាណូ ផែនទីស/ហា នេសាទចំនួន២ ផ្ទាំង | ផលិតនិងបោះផ្ទាំងប៉ាណូផែនទី | -គណៈកម្មការ<br>-សមាជិកស.ន<br>-មេភូមិ មេឃុំ | ២០១៦ | ២០១៧ |

### គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

**គោលបំណង**

-បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ

-ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រក និងប្រភពចំណីរបស់ត្រី និងសត្វ

-ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឲ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ ជាពិសេសធនធានជលផលនិងបរិស្ថាននិងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| កំណត់ និងរៀបចំតំបន់អភិរក្សអន្លង់វ៉ឺនឌុក | ទំហំ៧ហិកតា | - ត្រីគ្រប់ប្រភេទ<br>- សត្វទឹកគ្រប់ប្រភេទ<br>- ព្រៃលិចទឹកគ្រប់ប្រភេទ។ | - កំណត់ព្រំប្រទល់កន្លែងអភិរក្ស<br>- បោះបង្គោលដាក់ស្លាកសញ្ញាហាមឃាត់ដាក់ទង់សំគាល់ប៉ាណូផ្សព្វផ្សាយ<br>- ផ្សព្វផ្សាយសារៈប្រយោជន៍កន្លែងអភិរក្ស<br>-លែងកូនត្រី<br>-សង់រោងយាម<br>-ចុះល្បាតជាប្រចាំ | ២០១៦ | ២០១៨ | |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

**គោលបំណង**

-ថែរក្សា ការពារព្រៃលិចទឹកឲ្យនៅគង់វង្សយូរអង្វែង

-ទុកជាជម្រកត្រី និងសត្វពងកូន រក្សាលំនឹងបរិស្ថានក្នុងសហគមន៍នេសាទ

-បង្កើនទិន្នផលត្រីដើម្បីលើកកម្ពស់ជីវភាពរស់នៅ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ការពារថែរក្សាព្រៃលិចទឹកនៅសហគមន៍នេសាទភូមិថ្មី | ១០ ហិកតា | - ព្រៃលិចទឹកដែលត្រូវធ្វើការពារនូវប្រភេទ ឈើ រាំង ត្រស់ ទន្លា ឃ្លេ រំចេក និងប្រភេទព្រៃចំរុះផ្សេងៗ | - ផ្សព្វផ្សាអោយទូលាយពីសារសំខាន់ព្រៃលិចទឹក<br>- ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក<br>- ថែរក្សាចុះល្បាតជាប្រចាំ | ២០១៦ | ២០១៨ | |

**គ.៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

**គោលបំណង**

-បង្កើនប្រាក់ចំណូល

-កាត់បន្ថយការចាប់ត្រីក្នុងដែននេសាទ

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ៣០គ្រួសារចិញ្ចឹមត្រីអណ្តែងតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | -ជ្រើសរើសគ្រួសារកសិករចិញ្ចឹមត្រី<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីអណ្តែងដល់កសិករ<br>-ធ្វើអាងចិញ្ចឹមត្រី<br>-ផ្តល់កូនត្រី<br>-គ្រួតពិនិត្យតាមដាន | ៣០ អាង ទំហំ ២ម x ៤ម | ត្រីអណ្តែង | ១២.០០០ | ២០១៦ | ២០១៨ |
| ៣០គ្រួសារចិញ្ចឹមកង្កែបក្នុងស្រះ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត | ១៥ អាង ទំហំ ៤ម | កង្កែប | ១២.០០០ | ២០១៦ | ២០១៨ |

| | | | | | | |
|---|---|---|---|---|---|---|
| តាមបច្ចេកទេស ជាលក្ខណៈគ្រួសារ | - វគ្គបណ្ដុះបណ្ដាល បច្ចេកទេសចិញ្ចឹម កង្កែបដល់កសិករ ស្ម័គ្រចិត្ត<br>-ធ្វើស្រះចិញ្ចឹម<br>-ផ្ដល់កូនកង្កែប<br>-ត្រួតពិនិត្យតាមដាន | x ៥ម | | | | |

**គ.៦ ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព**

**គោលបំណង**

-ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរបង្កើនប្រាក់ចំណូល

-ជួយកាត់បន្ថយអត្រាចំណាកស្រុក

-ផ្ដល់ចំណេះដឹងជំនាញ និងបច្ចេកទេស (ចិញ្ចឹមត្រី សត្វ កសិកម្មសមស្រប)

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | បរិមាណ | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ៣០ គ្រួសារដាំបន្លែតាមបច្ចេកទេសលក្ខណៈគ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- វគ្គបណ្ដុះបណ្ដាលបច្ចេកទេសដាំបន្លែជាលក្ខណៈគ្រួសារ អនុវត្តផ្ទាល់<br>- ផ្ដល់ពូជបន្លែ<br>- ត្រួតពិនិត្យតាមដាន | គ្រាប់ពូជបន្លែ (ត្រកួន ត្រប់ ស្ពៃ ត្រសក់ ប៉េងប៉ោះ) | គ្រាប់ពូជ ៥ប្រភេទ | ២០១៦ | ២០១៨ |
| ៣០ គ្រួសារចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បណ្ដុះបណ្ដាលចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ<br>- ផ្ដល់ពូជ និងសំភារៈធ្វើ | ៦មាន់ ក្នុង ១គ្រួសារ | - ១៨០ ក្បាល | ២០១៦ | ២០១៨ |

| | | | | | |
|---|---|---|---|---|---|
| | ទ្រុង<br>-គ្រួតពិនិត្យតាមដាន | | | | |
| ៣០ គ្រួសារចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ<br>-អនុវត្តជាក់ស្តែងជាមួយគ្រួសារកសិកររៀបចំធ្វើទ្រុង<br>-ផ្តល់ពូជចិញ្ចឹម<br>-គ្រួតពិនិត្យតាមដាន | ១ជ្រូកក្នុង១គ្រួសារ | - ៣០ ក្បាល | ២០១៦ | ២០១៨ |
| ៣០ គ្រួសារបង្កើតធនាគារគោ/ក្របី | - ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍ក្រុម<br>-ផ្តល់ពូជ<br>- គ្រួតពិនិត្យតាមដាន | មេគោ/ក្របី | - ៥ក្បាល | ២០១៦ | ២០១៨ |

**គ.៧ ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ**

**គោលបំណង**

-ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរនិងមានដើមទុនសម្រាប់បង្កើនប្រាក់ចំណូល

-កាត់បន្ថយអត្រាការប្រាក់ខ្ពស់និងខ្ចីប្រាក់ពីឈ្មួញ

-ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ និងកែច្នៃផលនេសាទចំនួន ៣ | - ផ្សព្វផ្សាយជ្រើសរើសអ្នកទទួលផល | ២០១៦ | ២០១៨ | |

| | | | | |
|---|---|---|---|---|
| ក្រុម(៤៥ គ្រួសារ ) | - បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន លេខា និងហិរញ្ញឹក<br>- បង្កើតគោលការណ៍ក្រុម<br>- ផ្ដល់ទុនដល់ក្រុម<br>- ត្រួតពិនិត្យនិងតាមដាន | | | |
| ៧៥ គ្រួសារ បង្កើតក្រុមប្រើប្រាស់ទឹកស្អាត | - ផ្សព្វផ្សាយពីគោលបំណងគម្រោង<br>-សិក្សាប៉ាន់ប្រមាណអ្នកប្រើប្រាស់<br>- បោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រង<br>- បង្កើតគោលការណ៍ប្រើប្រាស់<br>- បណ្ដុះបណ្ដាលបច្ចេកទេស<br>- ផ្ដល់សម្ភារៈនិងអនុវត្ត<br>- ត្រួតពិនិត្យតាមដាន | ២០១៦ | ២០១៨ | |

**គ.៨ ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ**

**គោលបំណង**

-គណៈកម្មការសហគមន៍នេសាទមានភាពសកម្មក្នុងការងារ

-យល់ពីតួនាទី និងភារកិច្ចរបស់ពួកគាត់

-បង្កើនសាមគ្គីភាព និងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ

| សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | ២០១៦ | ២០១៨ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | ២០១៦ | ២០១៨ |
| បណ្ដុះបណ្ដាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០១៧ | ២០១៧ |
| បណ្ដុះបណ្ដាលការគ្រប់គ្រងថវិកា | ១លើក | ២០១៧ | ២០១៧ |

| | | | |
|---|---|---|---|
| បណ្តុះបណ្តាលចំណេះដឹងពីការសរសេរគម្រោងសំណើ | ១លើក | ២០១៧ | ២០១៨ |
| បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០១៨ | ២០១៨ |
| បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០១៨ | ២០១៨ |
| បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ២០១៨ | ២០១៨ |
| ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក | ២០១៨ | ២០១៨ |

**គ.៩ ផែនការបង្កើនការយល់ដឹងដល់សមាជិកសហាគមន៍នេសាទ**

**គោលបំណង**

-ដើម្បីបង្កើនសមត្ថភាពគណៈកម្មការ និងសមាជិកសហាគមន៍នេសាទ

-សមាជិកសហាគមន៍មានចំណេះដឹងដែលអាចផ្សព្វផ្សាយបន្តទៅសមាជិកផ្សេងទៀត

-កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហាគមន៍

| ផែនការ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយបង្កើនការយល់ដឹងដល់សមាជិកសហាគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ១ដង/១ឆ្នាំ | ២០១៦ | ២០១៨ |
| | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហាគមន៍ | ១ដង/១ឆ្នាំ | ២០១៦ | ២០១៨ |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហាគមន៍ | ១ដង/១ឆ្នាំ | ២០១៦ | ២០១៨ |
| | ផ្សព្វផ្សាយច្បាប់ជលផល/បរិស្ថាន/អនុក្រឹត | ១ដង/១ឆ្នាំ | ២០១៦ | ២០១៨ |

## គ.១០ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍន៍សហគមន៍

### គោលបំណង

-ដើម្បីឲ្យគណៈកម្មការ និងសមាជិកសហគមន៍នេសាទអនុវត្តផែនការបានជោគជ័យ

-មានផែនការយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការស្វែងរកប្រាក់ចំណូល

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព(អ្នកចូលថ្មី) | ២០១៦ | ២០១៨ | ២៥,៥ | ៦៨នាក់ |
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ២០១៦ | ២០១៨ | ១៧១ | ១៥២ គ្រួសារ |
| ភាគទានពីអ្នកនេសាទក្រៅសហគមន៍ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទក្រៅសហគមន៍ | ២០១៦ | ២០១៨ | ២.៧០០ | ៣០ ទូកx ២ថ្ងៃ/ខែ |
| | ប្រមូលប្រាក់ភាគទានអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ២០១៦ | ២០១៨ | ១.៥៣០ | ៣៤ទូកx ១ថ្ងៃ/ខែ |
| បដិភាគរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍សង្កាត់ | -បញ្ចូលផែនការអភិវឌ្ឍន៍សហគមន៍ទៅនឹងផែនការអភិវឌ្ឍន៍សង្កាត់<br>-ស្នើសុំប្រាក់បដិភាគពីឃុំដើម្បីអនុវត្តផែនការសហគមន៍នេសាទ | ២០១៦ | ២០១៨ | ៨៣.៧៦៨,៥ | |
| អង្គការក្រៅរដ្ឋាភិបាល | -ស្នើសុំថវិការសម្រាប់ប្រជុំប្រចាំខែ និងចុះល្បាត | ២០១៦ | ២០១៨ | | |

## ឃ.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឲ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម៖

-បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកគណៈ កម្មការ សហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ

-ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង នឹង បច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិចទឹកកន្លែង អភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រីការរកថវិកាទ្រទ្រង់ជាដើម

-រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញអង្គការនានា គម្រោងនិងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រនិងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ

-រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់

-ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកានិងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ

-កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ

-រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍

-ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ

-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ

-បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍សង្កាត់

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គួមិថ្មីរយៈពេល ៣ ឆ្នាំ (២០១៦-២០១៨)**

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| **១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | -កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទសហគមន៍<br>-កាត់បន្ថយបាននូវការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ក្នុងកន្លែងនេសាទហគមន៍<br>-សមាជិកសហគមន៍នេសាទនឹងចូលរួមអនុវត្តតាមប្រកាសស្តីពីការប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ | **១.១៥៥** | -គណៈកម្មការ<br>-សមាជិកស.ន | ២០១៦ | ២០១៨ | |
| ១.១ ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង ១ឆ្នាំ២ដង ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធ | | ៩០០ | | ២០១៦ | ២០១៨ | |
| ១.២ កំណត់ប្រភេទឧបករណ៍នេសាទ ទំហំ ចំនួនអ្នកនេសាទប្រចាំថ្ងៃ។ | | ១៣៥ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ១.៣ ត្រួតពិនិត្យ និង តាមដាន | | ១២០ | | ២០១៦ | ២០១៨ | |
| **២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍នេសាទ និងផ្ទាំងប៉ាណូ** | -បង្គោលចំនួន ៦ ដើមនឹងត្រូវបានបោះជាព្រំប្រទល់សហគមន៍នេសាទ និងផ្ទាំងប៉ាណូចំនួន ២ត្រូវបានបោះ<br>-កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់សហគមន៍<br>-សមាជិកនិងអ្នកនេសាទខាងក្រៅបានដឹងកន្លែងដែននេសាទ | **១.២៨០** | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ២.១ រៀបចំក្រុមទទួលខុសត្រូវ និងចាត់ចែងរកមធ្យោបាយបោះបង្គោលព្រំ ផ្ទាំងប៉ាណូសហគមន៍នេសាទ | | ៤០ | | ២០១៦ | ២០១៨ | |
| ២.២ យុទ្ធនាការបោះបង្គោលព្រំ | | ៤៤០ | | ២០១៦ | ២០១៨ | |
| ២.៣ ដាក់ប៉ាណូផ្សព្វផ្សាយជាសាធារណៈចំនួន២ផ្ទាំង | | ៨០០ | | ២០១៦ | ២០១៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| **៣.ផែនការកំណត់និងរៀបចំតំបន់អភិរក្សអន្លង់រ៉ែនខុក** | - ត្រីនិងសត្វគ្រប់ប្រភេទនឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍គ្រប់គ្រង<br>-សហគមន៍នឹងមានកន្លែងអភិរក្សច្បាស់លាស់<br>-ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្សនិងព្រំប្រទល់កន្លែងអភិរក្ស | **៤.០៥០** | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៣.១ កំណត់ព្រំប្រទល់កន្លែងអភិរក្ស | | ២០០ | | ២០១៦ | ២០១៨ | |
| ៣.២ បោះបង្គោលដាក់ស្លាកសញ្ញាហាមឃាត់ ដាក់ទង់សំគាល់ ប៉ាណូផ្សព្វផ្សាយ | | ១.០០០ | | ២០១៦ | ២០១៨ | |
| ៣.៣ ផ្សព្វផ្សាយពីសារៈប្រយោជន៍កន្លែងអភិរក្ស | | ២០០ | | ២០១៦ | ២០១៨ | |
| ៣.៤ លែងកូនត្រី | | ៥០០ | | ២០១៦ | ២០១៨ | |
| ៣.៥ សង់រោងយាម | | ៣៥០ | | ២០១៦ | ២០១៨ | |
| ៣.៦ ចុះល្បាតជាប្រចាំ | | ១.៨០០ | | ២០១៦ | ២០១៨ | |
| **៤.ផែនការគ្រប់គ្រង និងថែរក្សាព្រៃលិចទឹក** | -សមាជិកសហគមន៍នេសាទមានការយល់ដឹងពីការថែរក្សាការពារព្រៃលិចទឹក<br>-កាត់បន្ថយការកាប់ព្រៃលិចទឹក។ | **២.៤០០** | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៤.១ ផ្សព្វផ្សាយអោយទូលាយពីសារសំខាន់ព្រៃលិចទឹក | | ៣០០ | | ២០១៦ | ២០១៨ | |
| ៤.២ ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក | | ៣០០ | | ២០១៦ | ២០១៨ | |
| ៤.៣ ថែរក្សាចុះល្បាតជាប្រចាំ | | ១.៨០០ | | ២០១៦ | ២០១៨ | |
| **៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | -សមាជិកសហគមន៍នេសាទចំនួន៣០គ្រួសារចិញ្ចឹមត្រីអណ្តែងក្នុងអាងចំនួន ១២.០០០ក្បាល | **១៦.៤៦០** | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| **៥.១ ៣០គ្រួសារចិញ្ចឹមត្រីអណ្តែងក្នុងអាងលក្ខណៈគ្រួសារ** | | **១១.៦៨០** | | ២០១៦ | ២០១៨ | |
| ៥.១.១ ជ្រើសរើសគ្រួសារកសិករចិញ្ចឹមត្រី | | ២០០ | | ២០១៦ | ២០១៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥.១.២ បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមត្រីអណ្ដែងដល់កសិករ | -សមាជិកសហគមន៍នេសាទប្រមាណ ៦០% នឹងមានចំណេះដឹងលើការចិញ្ចឹមត្រីអណ្ដែងតាមលក្ខណៈបច្ចេកទេស<br>-នឹងជួយកាត់បន្ថយបានការនេសាទត្រីពីធម្មជាតិ<br>-បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍ | ៥០០ | | ២០១៦ | ២០១៨ | |
| ៥.១.៣ ធ្វើអាង និងដាក់កូនត្រីក្នុងអាង | | ៩.៩០០ | | ២០១៦ | ២០១៨ | |
| ៥.១.៤ ត្រួតពិនិត្យតាមដានរាល់ខែ | | ១.០៨០ | | ២០១៦ | ២០១៨ | |
| **៥.២ ៣០គ្រួសារចិញ្ចឹមកង្កែបក្នុងស្រះជាលក្ខណៈគ្រួសារ** | | **៤.៧៨០** | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៥.២.១ ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត | -សមាជិកសហគមន៍នេសាទចំនួន៣០គ្រួសារចិញ្ចឹមកង្កែបក្នុងស្រះចំនួន ១២.០០០ក្បាល<br>-សមាជិកសហគមន៍នេសាទប្រមាណ ៦០% នឹងមានចំណេះដឹងលើការចិញ្ចឹមត្រីអណ្ដែងតាមលក្ខណៈបច្ចេកទេស<br>-បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍។ | ២០០ | | ២០១៦ | ២០១៨ | |
| ៥.២.២ បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមកង្កែបដល់កសិករស្ម័គ្រចិត្ត | | ៥០០ | | ២០១៦ | ២០១៨ | |
| ៥.២.៣ ជីកស្រះ និងដាក់កូនកង្កែប | | ៣.០០០ | | ២០១៦ | ២០១៨ | |
| ៥.២.៤ ត្រួតពិនិត្យតាមដានរាល់ខែ | | ១.០៨០ | | ២០១៦ | ២០១៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦.ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព | | ១៧.១៨០ | | | | |
| ៦.១ ៣០គ្រួសារដាំបន្លែតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | - គ្រួសារកសិករចំនួន ៣០ គ្រួសារ ទទួលគ្រាប់ពូជបន្លែ | ៩.៦៨០ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៦.១.១ ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត | - គ្រួសារកសិករប្រមាណ ៨០% នឹងមានចំណេះដឹងលើបច្ចេកទេសធ្វើសួនបន្លែជាលក្ខណៈគ្រួសារ | ៦០០ | | ២០១៦ | ២០១៨ | |
| ៦.១.២ បណ្តុះបណ្តាលបច្ចេកទេសដាំបន្លែជាលក្ខណៈគ្រួសារ និងអនុវត្តផ្ទាល់ | | ១.៥០០ | | ២០១៦ | ២០១៨ | |
| ៦.១.៣ ផ្តល់គ្រាប់ពូជបន្លែ | | ១.៥០០ | | ២០១៦ | ២០១៨ | |
| ៦.១.៤ គ្រួតពិនិត្យតាមដាន | - បង្កើនមុខរបរ និងប្រាក់ចំណូលដល់គ្រួសារកសិករ | ១.០៨០ | | ២០១៦ | ២០១៨ | |
| ៦.២ ១៥គ្រួសារចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | -សមាជិកសហគមន៍នេសាទចំនួន១៥គ្រួសារចំនួន៧៥មេ និងឈ្មោល១៥មាន់ | ៣.១៨០ | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៦.២.១ ជ្រើសរើសអ្នកស្ម័គ្រចិត្ត | | ៦០០ | | ២០១៦ | ២០១៨ | |
| ៦.២.២ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ | -បង្កើនមុខរបរដល់សមាជិកសហគមន៍នេសាទ | ១.៥០០ | | ២០១៦ | ២០១៨ | |
| ៦.២.៣ ផ្តល់ពូជ និង ទិញសំភារៈ ធ្វើទ្រុង | -សមាជិកសហគមន៍នេសាទប្រមាណ៦០%យល់ដឹងលើបច្ចេកទេសចិញ្ចឹមមាន់តាមលក្ខណៈគ្រួសារ | ៧២០ | | ២០១៦ | ២០១៨ | |
| ៦.២.៤ គ្រួតពិនិត្យ និងតាមដាន | -បង្កើនប្រាក់ចំណូលដល់សហគមន៍នេសាទ | ១.០៨០ | | ២០១៦ | ២០១៨ | |

| | | | | | | |
|---|---|---|---|---|---|---|
| **៦.៣ ៣០ គ្រួសារចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ** | -សមាជិកសហគមន៍នេសាទចំនួន៣០គ្រួសារនិងចំនួនមេជ្រូក៣០<br>-បង្កើនមុខរបរដល់សមាជិកសហគមន៍នេសាទ<br>-សមាជិកសហគមន៍នេសាទប្រមាណ៦០%យល់ដឹងលើបច្ចេកទេសចិញ្ចឹមជ្រូកតាមលក្ខណៈគ្រួសារ<br>-ជួយកាត់បន្ថយការនេសាទត្រីពីធម្មជាតិ<br>-បង្កើនប្រាក់ចំណូលដល់សហគមន៍នេសាទ | **៦.៤៨០** | -សហគមន៍ស.ន<br>-រាជរដ្ឋាភិបាល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០១៦ | ២០១៨ | |
| ៦.៣.១ ជ្រើសរើសអ្នកស្ម័គ្រចិត្ត | | ៦០០ | | ២០១៦ | ២០១៨ | |
| ៦.៣.២ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ | | ១.៥០០ | | ២០១៦ | ២០១៨ | |
| ៦.៣.៣ អនុវត្តជាក់ស្តែងជាមួយគ្រួសារកសិករៀបចំធ្វើទ្រុង | | ៩០០ | | ២០១៦ | ២០១៨ | |
| ៦.៣.៤ ផ្តល់ពូជចិញ្ចឹម | | ២.៤០០ | | ២០១៦ | ២០១៨ | |
| ៦.៣.៥ ត្រួតពិនិត្យនិងតាមដាន | | ១.០៨០ | | ២០១៦ | ២០១៨ | |
